N° 1
08-1-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ១ ថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៩៧

OFFICIAL JOURNAL

រាជកិច្ច

1997.
Jan.

រួមមាន :

- ច្ប
- ព្រះ
- អនុ
- ប្រ
- សេ
- ស

LAU

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រឹត្យ

០៣_០១_១៩៩៧_ ព្រះរាជក្រឹត្យលេខ នស.រកត ០១៩៧/០១ តែងតាំងលោក LIU CHIN MU ជាឧកញ៉ា ១

II -ទីស្តីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

០៦-០១-១៩៩៧- អនុក្រឹត្យលេខ ០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២

២_សេចក្តីសំរេច

០២_០១_១៩៩៧_ សេចក្តីសំរេចលេខ ០១ សសរ. ស្តីពីការផ្ទេរសិទ្ធិ ៣

០៣_០១_១៩៩៧_ សេចក្តីសំរេចលេខ ០២ សសរ ស្តីពីការផ្ទេរសិទ្ធិ ៤

III - ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

០២-០១-១៩៩៧- ប្រកាសលេខ ០១ ផក.ប្រក អនុញ្ញាតអោយសិប្បកម្មផលិតសំភារៈអំពីដែកអីណុក មានលោក ឈិន គីមសេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការផលិតកម្ម ៥

០៦_០១_១៩៩៧_ ប្រកាសលេខ ០២ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហ្គ្រែន ថិច អិន ធើណាស្យូណាល់ (GRANDTEX INTERNATIONAL) តំណាងដោយលោក LIU KUNG SHENG សញ្ជាតិតៃវ៉ាន់បង្កើត «រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ» មានឈ្មោះថា «រោងចក្រកាត់ដេរសំលៀកបំពាក់ ហ្គ្រែនថិច អិនធើណាស្យូណាល» ៦

២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០២_០១_១៩៩៧_ ប្រកាសលេខ ០០១/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រី រាជការ ៧

០២_០១_១៩៩៧_ ប្រកាសលេខ ០០២/៩៧ ពម.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការ ៨

០២_០១_១៩៩៧_ ប្រកាសលេខ ០០៣/៩៧ ពម.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការ ៩

០២_០១_១៩៩៧_ ប្រកាសលេខ ០០៤/៩៧.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការ ១១

២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

ប្រកាស

០២_០១_១៩៩៧_ ប្រកាសលេខ ០០១ ប្រក.កសកចត ស្តីពីការផ្ទេរ មជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្មពីមន្ទីរ មកជានាយកដ្ឋានផែនការស្ថិតិ ១២

០២_០១_១៩៩៦_ ប្រកាសលេខ ០០០២ ប្រក.កសក.ចត ស្តីពីកាបង្កើតស្ថានីយ៍ស្រាវជ្រាវផលផល ១៣

៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

០៨_០១_១៩៩៧_ ប្រកាសលេខ ១២ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាដំបងដែក មកជាសាលាមបឋមសិក្សាសម្តេចហ៊ុន សែន ដំបងដែក ១៥

០៨_០១_១៩៩៧_ ប្រកាសលេខ ១៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលា
បឋមសិក្សារការអារ មកជាសាលាបឋមសិក្សា ហ៊ុន សែន រការអារ ១៦

០៨_០១_១៩៩៧_ ប្រកាសលេខ ១៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលា
បឋមសិក្សាឈើទាល មកជាសាលាបឋមសិក្សា ហ៊ុន សែន ឈើទាល ១៨

០៨_០១_១៩៩៧_ ប្រកាសលេខ ១៥ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលា បឋមសិក្សា
«កំពង់ជ័យ» មកជាសាលាបឋមសិក្សា «ហ៊ុន សែន កំពង់ជ័យ» ១៩

៤_ ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

០៨_០១_១៩៩៧_ ប្រកាសលេខ ០០៥ បទប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២០

៥_ ទីស្តីការក្រសួងធម្មការ និងសាសនា

០៦_០១_១៩៩៧_ ប្រកាសលេខ ០១/៩៧ កធ.សនធ ស្តីពីការអនុញ្ញាត និង
ទទួលស្គាល់ សមាគមមូលនិធិអភិវឌ្ឍពុទ្ធិកសិក្សា ២២

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៧/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រ កម្ពុជា

* * *

តែងតាំង

លោក LIU CHIN MU

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យ លេខ ០១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិជូនលោកសាស្ត្រាចារ្យ Pierre CARTERET ទីប្រឹក្សាបារាំងនៅមហាវិទ្យាល័យវេជ្ជសាស្ត្រ និសថសាស្ត្រ និងទន្តសាស្ត្រ ដែលបានខិតខំខ្នះខ្នែងអស់ពីកំលាំងកាយចិត្ត ក្នុងការផ្តល់ជំនួយរៀបចំអោយប្រសើរឡើង នូវផ្នែកឯកទេសវេជ្ជសាស្ត្រ និងការងារគ្រប់គ្រងមហាវិទ្យាល័យ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

២_សេចក្តីសំរេច

ភ្នំពេញថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០១ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ខណ្ណ មូលីខណ្ណី**

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាទេសរដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកនគរូបនីយកម្មនិងវប្បធម៌ ជំនួសឯកឧត្តម

ទេសរដ្ឋមន្ត្រី **ខណ្ណ មូលីខណ្ណ** ដែលបានច្បាប់ឈប់សំរាកព្យាបាលជម្ងឺ ចាប់ពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **គាត ឈន់** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ០២ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋលេខាធិការកិច្ចការនារី

សម្រេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **នួច កាណុន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋលេខាធិការស្តីទី នៃក្រសួងកិច្ចការនារី ជំនួសឯកឧត្តម **កៀន សុគន្ធ** ដែលបានច្បាប់ឈប់សំរាកព្យាបាលជម្ងឺ ចាប់ពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **នួច កាណុន** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ០១ ឧក.ប្រក ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : _អនុញ្ញាតអោយសិប្បកម្មផលិតសំភារៈ អំពីដែកអ៊ីណុកដែលមាន លោក ឈិន គីមសេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៩១៤៣ ភ.ព ចុះថ្ងៃទី ១៦_០១_៩២ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥១អឺ១ ផ្លូវ លេខ ១៦៦ ក្រុមទី ៥ សង្កាត់អូរឫស្សី៣ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បើកដំណើរ ការផលិតកម្ម នៅក្នុងទីតាំង ភូមិទឹកថ្លា សង្កាត់សំរោងក្រោម ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក ឈិន គីមសេង ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល សំភារៈអំពីដែកអ៊ីណុក ហ្វឹង_អ៊ីង ' FENG-YING' សញ្ញា ' FY' ស្របតាមគំរូផ្លាកសញ្ញា និងសញ្ញាសំគាល់ ដែលបានដំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ០២ ឧក.ប្រក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : _អនុញ្ញាតអោយក្រុមហ៊ុន ហ្គ្រែនថិច អ៊ិនធើណាស្យូណល (GRANDTEX INTERNATIONAL Co; LTD) តំណាងដោយលោក LIU KUNG SHENG សញ្ជាតិ តៃវ៉ាន់ អាយុ ៥៩ឆ្នាំ ភេទប្រុស អាសយដ្ឋាន N' 23 JALNA BELIMBING 81400 SENAT JOHOR MALAYSIA កាន់លិខិតឆ្លងដែនលេខ M11274661 ចុះថ្ងៃទី ០១_១១_៩៥ បង្កើត**«រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ»** ដែលមានឈ្មោះ**«រោងចក្រកាត់ដេរសំលៀកបំពាក់ហ្គ្រែនថិចអ៊ិនធើណាស្យូណល»** មានទីតាំងស្ថិតនៅឡូតិ៍លេខ ១៧៧១ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ដែលបានដំកល់ទុក នៅក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល **«សំលៀកបំពាក់»** ទៅតាមគំរូដែលដំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែង ខាងលើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
អ៊ុត ឬរ៉ាំង

* * *

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាស លេខ ០០១/៩៧ ពម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

2½បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០១៩៦/១៤/នស/រកម. ចុះថ្ងៃទី ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងពតិមានច្បាប់
- យោងតាមសំណើលេខ ៤៧៧/៩៦ សពខ.ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ របស់ទីភ្នាក់ងារ សារពតិមានខ្មែរ SPK
- យោងតាមតម្រូវការចាំបាច់

- ពិនិត្យលើលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **រស់ ឈារិទ្ធ** ជាអនុប្រធាននាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋានទីភ្នាក់ ងារសារពត៌មានខ្មែរ AKP ក្រសួងពតមាន ។

ប្រការ ២ : ឯកឧត្តមអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោករគ្គនាយកទី ភ្នាក់ងារសារពត៌មានខ្មែរ AKP លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ហិរញ្ញវត្ថុ និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

ភ្នំពេញថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០០២/៩៧ ពម.ប្រក

ស្តីពីការផ្ទេរមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពតិមាន ។
- យោងតាមតម្រូវការចាំបាច់ នៃទីស្តីការរដ្ឋមន្ត្រី

សម្រេច

ប្រការ ១ : ផ្ទេរលោក **ចាស់ សំអោត** បុគ្គលិកនាយកដ្ឋាននិពន្ធក្រៅប្រទេស អគ្គនាយកដ្ឋានវិទ្យុជាតិ កម្ពុជា នៃក្រសួងពត៌មាន អោយមកបំរើការងារនៅអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក **ចាស់ សំអោត** អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ត្រូវសំរួលផ្ទេរមកទីស្តីការរដ្ឋមន្ត្រី ក្នុងករណីសមស្រប ។

ប្រការ ៣ : ឯកឧត្តមអគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោកអគ្គនាយកវិទ្យុជាតិកម្ពុជា លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ហិរញ្ញវត្ថុ និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
អៀង មូលី

* * *

ភ្នំពេញថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាស លេខ ០០៣/៩៧ ពម.ប្រក

ស្តីពីការផ្ទេរមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន ។

- យោងចំណារឯកភាពលេខ ៣៣៦/៩៦ សពខ ចុះថ្ងៃទី ១៥/០៨/១៩៩៦ របស់អគ្គនាយក ដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ " អា.កា.ប៉េ. "
- យោងតម្រូវការចាំបាច់ នៃទីស្តីការរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : ផ្ទេរមន្ត្រីរាជការចំនួន ០២រូប នៅអគ្គនាយកដ្ឋានទីភ្នាក់ងារសារពតិមានខ្មែរ " អាកាប៉េ " អោយមកបំរើការងារនៅការិយាល័យបូកសរុប នាយកដ្ឋានរដ្ឋបាល នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពតិមាន ដូចមានរាយនាមខាងក្រោម ÷

១_លោក **លឹម ឈៀង**

២_លោក **ទ៉ាន់ ស៊ីណា**

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួន ត្រូវសំរួលផ្ទេរពីអគ្គនាយកដ្ឋានទីភ្នាក់ងារ សារពតិមានខ្មែរ " អាកាប៉េ " មកទីស្តីការក្រសួងវិញ ។

ប្រការ ៣ : ឯកឧត្តមអគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោកអគ្គនាយកទីភ្នាក់ងារ សារពតិមានខ្មែរ " អាកាប៉េ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ហិរញ្ញវត្ថុ និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

ភ្នំពេញថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាស លេខ ០០៤/៩៧ ពម.ប្រក

ស្តីពីការផ្ទេរមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- ពិនិត្យពាក្យសុំផ្ទេរកន្លែងធ្វើការរបស់សាមីខ្លួន

សំរេច

ប្រការ ១ : ផ្ទេរលោក **ឈឹម រិទ្ធី** អនុប្រធានការិយាល័យរដ្ឋបាល នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា អោយមកបំរើការងារនៅនាយកដ្ឋានបូកសរុប នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ នៃក្រសួងពត៌មាន ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក **ឈឹម រិទ្ធី** អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ត្រូវសំរួលផ្ទេរមកទីស្តីការរដ្ឋមន្ត្រីក្នុងករណីសមស្រប ។

ប្រការ ៣ : ឯកឧត្តមអគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោកអគ្គនាយកវិទ្យុជាតិកម្ពុជា លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ប្រកាស

ភ្នំពេញថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាស លេខ ០០០១ ប្រក.កសក.ចត

ស្តីពីការផ្ទេរមជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេស

កសិកម្មពីមន្ទីរ មកនាយកដ្ឋានផែនការ-ស្ថិតិ

* * *

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលមាសសភាពរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម ០១៩៦-១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់តួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញ ប្រកាសលេខ ៣២៩ ប្រក.កសក.ចត ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ការចាំបាច់របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរ មជ្ឈមណ្ឌលឯកសារ វិទ្យាសាស្ត្រ បច្ចេកទេសកសិកម្ម Agricultural Scientific Dcoumentation centre (ASDC) អោយស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់ របស់នាយកដ្ឋាន ផែនការ ស្ថិតិ វិញនិងមានថ្នាក់ស្មើការិយាល័យ ។

ប្រការ ២ : រាល់ខ្លឹមសារដូចមានចែងក្នុងប្រកាសលេខ ៣២៩ ប្រក.កសក.ចត ចុះថ្ងៃទី ០៤ ខែ មិថុនា និងនេសាទ ឆ្នាំ ១៩៩៦ នៅរក្សាតំលៃដដែល លើកលែងតែប្រការ ១ ។

ប្រការ ៣ : មជ្ឈមណ្ឌលឯកសារ វិទ្យាសាស្ត្រ បច្ចេកទេសកសិកម្ម មានភារកិច្ចបន្ថែមទៀត គឺធ្វើការ ណែនាំអំពីការគ្រប់គ្រងបណ្ណាល័យរបស់គ្រប់អង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង មន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទខេត្ត ក្រុង នានា ។

ប្រការ ៤ : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន ផែនការ ស្ថិតិ ប្រធាននាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធនានា ត្រូវទទួលបន្ទុក អនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាត ទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សេងហួរ

* * *

ភ្នំពេញថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាស លេខ ០០២ ប្រក.កសក.ចត

ស្តីពីការបង្កើតស្ថានីយស្រាវជ្រាវផលផល

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះ រាជក្រឹត្យលេខ នស.រកត ១០៩៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស.រកម ០១៩៦.១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

- បានឃើញអនុក្រឹត្យលេខ ១៨ អន.ក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្ដីពីការកំណត់តួនាទីភារកិច្ច និងរចនាសម្ព័ន្ធ ចាត់តាំងរបស់ក្រសួងកសិកម្ម
- តាមសំណើ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តសៀមរាប

សំរេច

ប្រការ ១ : បង្កើតស្ថានីយ៍ស្រាវជ្រាវផលផល ក្នុងនាទីព្រៃលិចទឹក ខេត្តសៀមរាប ២ កន្លែង ដូចមាន ផែនទីក្នុងឧបសម្ព័ន្ធគឺ :

–ទី ១ មានទីតាំងនៅក្នុង ឃុំ កំពង់ឃ្លាំង ស្រុក សូត្រនិគម

–ទី ២ មានទីតាំងនៅក្នុងឃុំ ចុងឃ្នៀស ស្រុក សៀមរាប

ប្រការ ២ : តួនាទី ភារកិច្ចជាក់ស្ដែងរបស់ស្ថានីយ៍ស្រាវជ្រាវផលផលនីមួយៗ អាស្រ័យដោយប្រធាន មន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទខេត្តសៀមរាបកំណត់សំរេចដោយមានយោបល់ ឯកភាពពីប្រធាននាយកដ្ឋានជលផល ។

ប្រការ ៣ : ស្ថានីយ៍ស្រាវជ្រាវផលផលដូចមានក្នុងប្រការ ១ ជាផ្នែកមួយស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំរបស់ការិយាល័យជលផល នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តសៀមរាប ។

ប្រការ ៤ : ស្ថានីយស្រាវជ្រាវផលផលគ្រប់គ្រង ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយរូបជំនួយការ ។

ប្រការ ៥ : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន ផែនការ ស្ថិតិ ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះរៀងៗខ្លួនចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សេងហួរ

* * *

៤_ នីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

ភ្នំពេញថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាស លេខ ១២ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាដីបងដែក មកជា

សាលាបឋមសិក្សា សម្តេច ហ៊ុន សែន ដីបង ដែក

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំ យុជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃ គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើប្រាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤
- បានឃើញ ព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ សន.រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦-៧-៩៦ ស្តីពីប្រព័ន្ធ អប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានឃើញ លិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ចាម លេខ ៣៨១ អយក.បឋ.មគស ចុះថ្ងៃទី ១៦-៨-៩៦
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានចំនេះទូទៅ និង មេត្តយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡាខេត្ត កំពង់ចាម ប្តូឈ្មោះ សាលាបឋមសិក្សា ដីបងដែក ដែលមានទីតាំងស្ថិតនៅឃុំកោះរកា ស្រុកកំពង់សៀមខេត្តកំពង់ចាម មកជា «សាលាបឋមសិក្សា សម្តេច ហ៊ុន សែន ដីបងដែក»វិញចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ នេះ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយក ដ្ឋានផែនការ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មេត្តយ្យសិក្សា ប្រធាន មន្ទីរ អប់រំ យុវជន និង កីឡាខេត្ត កំពង់ចាម ប្រធានការិយាល័យអប់រំ យុវជន និង កីឡា ស្រុក កំពង់សៀម នាយកសាលាបឋមសិក្សាសម្តេច ហ៊ុន សែន ជិបងដែក មានភារកិច្ច អនុវត្ត ប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សារុន

* * *

ភ្នំពេញថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៣ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ករារ មកជា

សាលាបឋមសិក្សា ហ៊ុន សែន ករារ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ សន.រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦-៧-៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ១២ឆ្នាំ ។
- បានពិនិត្យលិខិតស្នើសុំ របស់គណៈកម្មការទ្រទ្រង់សាលាការអារ ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត កំពង់ចាម ចុះថ្ងៃទី ២៤-៦-៩៦ ព្រមទាំង ចំណារឯកភាពរបស់ឯកឧត្តមអភិបាលខេត្ត កំពង់ចាម ចុះថ្ងៃទី ០៩-៧-៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡាខេត្តកំពង់ចាម ប្តូរឈ្មោះសាលាបឋមសិក្សា រការអារ ដែលមានទីតាំងស្ថិតនៅឃុំរការអារ ស្រុកកងមាស ខេត្តកំពង់ចាម មកជា«សាលាបឋមសិក្សា ហ៊ុន សែន រការអារ »វិញចាប់ពីឆ្នាំសិក្សា១៩៩៦-៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : លោកប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា លោកប្រធាននាយកដ្ឋានចាត់តាំង លោក ប្រធាននាយកដ្ឋាន ផែនការហិរញ្ញកិច្ច លោកប្រធាននាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យ សិក្សាលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម លោកប្រធានការិយាល័យ អប់រំ យុវជន និងកីឡាស្រុកកងមាស លោកនាយកសាលាបឋមសិក្សា ហ៊ុន សែន រការអារ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
គា សាឃាន

* * *

ភ្នំពេញថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៤ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ឈើទាល

មកជាសាលាបឋមសិក្សា «ហ៊ុន សែន ឈើទាល»

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០-៧-៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ សន.រកត ០៧៩៦-៩២ ចុះថ្ងៃទី ២៦-៧-៩៦ ស្តីពីប្រព័ន្ធអប់រំ នេះទូទៅ១២ឆ្នាំ
- បានឃើញលិខិតស្នើសុំ របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩២
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម ប្តូរឈ្មោះសាលាបឋមសិក្សា ឈើទាលដែលមានទីតាំងស្ថិតនៅឃុំ ពាមជីលាំង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមមកជា «សាលាបឋមសិក្សា ហ៊ុន សែន ឈើទាល »វិញចាប់ពីឆ្នាំសិក្សា១៩៩៦-៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : លោកប្រធានមន្ទីរក្រសួងអប់រំ យុវជន និងកីឡា លោកប្រធាននាយកដ្ឋានបាត់តាំងលោក ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច លោកប្រធាននាយកដ្ឋានចំនេះ

ទូទៅនិងមត្តេយ្យសិក្សា លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកត្បូងឃ្មុំ លោកនាយកសាលាបឋមសិក្សា ហ៊ុន សែន ឈើទាល មាន ភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាមាន

* * *

ភ្នំពេញថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាស លេខ ១៥ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «សំពងជ័យ»

មកជា សាលាបឋមសិក្សា «ហ៊ុន សែន–សំពងជ័យ»

* * *

រដ្ឋមន្ត្រី ក្រសួង អប់រំ យុវជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ សន.រកត ០៧៩៦–៥២ ចុះថ្ងៃទី ២៦–៧–៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានពិនិត្យ លិខិតស្នើសុំរបស់គណៈកម្មការមាបិតាសិក្សា សាលាបឋមសិក្សា «សំពងជ័យ»លេខ ១៣ អយក.សពជ ចុះថ្ងៃទី ១៦–៦–៩៦
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ចាម ប្តូរឈ្មោះសាលាបឋមសិក្សា សំពងជ័យ នៅឃុំ សំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាមមកជាសាលាបឋមសិក្សា ហ៊ុន សែន សំពងជ័យ»វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : លោកប្រធានមន្ទីរក្រសួងអប់រំ យុវជន និងកីឡា លោកប្រធាននាយកដ្ឋានបាត់តាំង លោកប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច លោក ប្រធាននាយកដ្ឋានបំនេះទូទៅ និងមត្តេយ្យ សិក្សា លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តកំពង់ចាម លោកប្រធានការិយាល័យ អប់រំ យុវជន និង កីឡាស្រុក ជើងព្រៃ លោកនាយកសាលាបឋមសិក្សា «ហ៊ុន សែន–សំពងជ័យ»មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាហាន

* * *

៥_និស្តិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

ភ្នំពេញថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០០៥ បន.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តមសីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ នស ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមស្តីពីសហលក្ខន្តិកមន្ត្រីរាជការស៊ីវិល លេខ ០៦ ន.ល៩៤ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម សន.រកម ០១៩៦-២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ស្តីពីបង្កើត ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញសំណើរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តបាត់ដំបង និង ពិនិត្យសមត្ថភាពមន្ត្រី បុគ្គលិករាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រី បុគ្គលិក រាជការចំនួន ០៤ រូប នៅមន្ទីរប្រៃសណីយ៍និង ទូរគមនាគមន៍ខេត្ត បាត់ដំបងដូចមានរាយនាមខាងក្រោមអោយទទួលតួនាទី និងភារកិច្ច ដូចតទៅ :

១-លោក ភឿង ឌី ប្រធានការិយាល័យប្រៃសណីយ៍ស្រុក បាណន់ ជាបណ្តោះអាសន្ន

២-លោក ផេង លេខ ប្រធានការិយាល័យប្រៃសណីយ៍ស្រុក ឯកភ្នំ ជាបណ្តោះអាសន្ន

៣-លោក ញាន រឿង ប្រធានការិយាល័យប្រៃសណីយ៍ និងទូរគមនាគមន៍ស្រុក បាត់ដំបងជាបណ្តោះអាសន្ន

៤-ឡើង វុទ្ធិ ប្រធានការិយាល័យប្រៃសណីយ៍ ស្រុក បវេលជាបណ្តោះអាសន្ន

ប្រការ ២ : មន្ត្រីរាជការចំនួន ០៤រូប ដូចមានចែងក្នុងប្រការ១ ខាងលើត្រូវអនុវត្តតាមតួនាទី ភារកិច្ច និង ក្នុងសមត្ថកិច្ចរបស់ខ្លួន ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្តបាត់ដំបងសាមីខ្លួនទាំង ០៤រូប ត្រូវទទួលអនុវត្តន៍តាមខ្លឹមសារនៃ ប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

សុ ឃុន

* * *

៦_ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

ភ្នំពេញថ្ងៃទី ០៦ ខែមករា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០១/៩៧ កធស.ឧធ

ស្តីពីការអនុញ្ញាតនិងទទួលស្គាល់សមាគម

មូលនិធិអភិវឌ្ឍន៍ពុទ្ធិកសិក្សា

* * *

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ :នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ។
- បានឃើញ អនុក្រឹត្យលេខ :២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃក្រសួងធម្មការ និងសាសនា

– បានឃើញពាក្យស្នើសុំរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលសមាគមមូលនិធិអភិវឌ្ឍន៍ពុទ្ធិកសិក្សា ចុះថ្ងៃទី៦– ១១–៩៦ បានស្នើសុំបង្កើតសមាគមមូលនិធិអភិវឌ្ឍន៍ ពុទ្ធិកសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតនិងទទួលស្គាល់សមាគម «មូលនិធិអភិវឌ្ឍន៍ពុទ្ធិកសិក្សា» «សរសេរជាអក្សរកាត់ថា » ស.ម.អ.ព ដែលមាន ទីស្នាក់ការនៅកុដិលេខ ១៥ វត្តនាគវ័ន សង្កាត់បឹងកក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : សមាគមនេះ មានគោលបំណងជួយបណ្ដុះបណ្ដាល ជួយឧបត្ថម្ភចំពោះព្រះសង្ឃ និងកិច្ចអភិវឌ្ឍន៍ធនធានមនុស្សផ្នែកពុទ្ធិកសិក្សា ដើម្បីអោយមានភាពរុងរឿងនិងរីកចំរើនសមស្រប តាមការវិវត្តន៍របស់សង្គមជាតិ ។

ប្រការ ៣ : សមាគមនេះត្រូវគោរពអោយបានត្រឹមត្រូវតាមលក្ខន្តិកៈរបស់ខ្លួន ច្បាប់ព្រះរាជាណាចក្រ កម្ពុជានិងបទបញ្ញត្តិទាំងឡាយរបស់អាជ្ញាធិការដ្ឋាន នៃពុទ្ធិកសិក្សាព្រមទាំងបទបញ្ញត្តិទាំងឡាយរបស់ក្រសួងធម្មការ និងសាសនា ។

ប្រការ ៤ : សមាគមមូលនិធិអភិវឌ្ឍន៍ពុទ្ធិកសិក្សា នាយកដ្ឋានធម្មការ អគ្គាធិការដ្ឋាន ពុទ្ធិកសិក្សា មន្ទីរ ធម្មការនិងសាសនាគ្រប់ខេត្ត ក្រុង ព្រះមេគណគ្រប់ខេត្ត ក្រុង ព្រមទាំងស្ថាប័នរដ្ឋអំណាច ថ្នាក់គ្រប់លំដាប់ថ្នាក់ ដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្ដីសម្រេចនេះ អោយបានល្អប្រសើរ ។

ប្រការ ៥ : សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ហៀង វណ្ណារិទ្ធ

* * *

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ៨០០ រៀល